**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**លេខៈ......២.៧.....ស.ភ.វ......**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សាពិន័យនិងលើកសរសើរ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤
- យោងប្រកាសលេខ ១៦១ប្រក. ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាពិន័យនិងលើកសរសើរ ដើម្បីពិនិត្យ វាយតម្លៃ និងសម្រេចលើការដាក់ពិន័យ ឬផ្តល់ការលើកសរសើរ ចំពោះសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងសិល្បៈ ប្រពៃណី ទំនៀមទម្លាប់ និងសីលធម៌សង្គម សំដៅចូលរួមលើកស្ទួយអត្តសញ្ញាណវប្បធម៌ សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- ឯកឧត្តម | **ហាប់ ទូច** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- ឯកឧត្តម | **ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- លោកជំទាវ | **ហ៊ូ និរមិត្តា** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥- ឯកឧត្តម | **យន់ ខៀន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |

៦- ឯកឧត្តម **ហ៊ីម សុផិត្យា** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន. សមាជិក
៧- ឯកឧត្តម **ចំរើន ផ៉ាន់ថា** ទីប្រឹក្សាអមក្រសួងវប្បធម៌និងវិចិត្រសិល្បៈ. សមាជិក
៨- ឯកឧត្តម **ស៊ីយ៉ុន សុភារិទ្ធ** អគ្គនាយកបច្ចេកទេសវប្បធម៌ក្រ.វ.វ.ស. សមាជិកអចិន្ត្រៃយ៍
៩- លោក **ម៉ុក ខេមរ៉ា** ប្រធាននាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិក
ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
១០- លោកឧត្តមសេនីយ៍ទោ **ស៊ឹម ឈាន់** អនុប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា
ក្រសួងមហាផ្ទៃ សមាជិក
១១- ប្រធានសមាគមទូរទស្សន៍កម្ពុជា សមាជិក
១២- ប្រធានសមាគមវិទ្យុកម្ពុជា សមាជិក
១៣- ប្រធានសមាគមភាពយន្តកម្ពុជា សមាជិក
១៤- ប្រធានសមាគមសិល្បករខ្មែរ សមាជិក
១៥- ប្រធានសមាគមសិល្បករស្ម័គ្រចិត្តជួយសង្គម សមាជិក
១៦- ប្រធានសមាគមពិធីករ ពិធីការិនីកម្ពុជា សមាជិក
១៧- ប្រធានសមាគមអ្នកនិពន្ធខ្មែរ សមាជិក
១៨- តំណាងសមាគមមិត្តអ្នកបញ្ចូលសំឡេង សមាជិក

ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ មានភារកិច្ចដូចខាងក្រោម៖

- ប្រឹក្សាយោបល់ និងផ្តល់អនុសាសន៍ដល់ក្រុមលេខាធិការដ្ឋាន ក្នុងការអនុវត្តការដាក់ពិន័យ និងការលើកសរសើរ ចំពោះសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងសិល្បៈ ប្រពៃណី ទំនៀមទម្លាប់ និងសីលធម៌សង្គម
- ពិនិត្យ វាយតម្លៃ និងសម្រេចលើការដាក់ពិន័យ ចំពោះអ្នកដែលបានធ្វើសកម្មភាពនាំឱ្យប៉ះពាល់ដល់សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់ជាតិ និងសីលធម៌សង្គម ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ វាយតម្លៃ និងសម្រេចផ្តល់ការលើកសរសើរ ចំពោះអ្នកដែលបានរួមចំណែកលើកកម្ពស់សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់ជាតិ និងសីលធម៌សង្គម
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តការដាក់ពិន័យ និងការលើកសរសើរ។

**ប្រការ២.-**

ត្រូវបានបង្កើតក្រុមលេខាធិការដ្ឋានមួយ ជាជំនួយការឲ្យក្រុមប្រឹក្សាពិន័យនិងលើកសរសើរ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ចំរើន ផ៉ាន់ថា** ទីប្រឹក្សាអមក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធាន
២-លោកជំទាវ **ហ៊ី និរមិត្តា** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី អនុប្រធាន
៣-លោកឧត្តមសេនីយ៍ទោ **ស៊ឹម ឈាន់** អនុប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា
ក្រសួងមហាផ្ទៃ អនុប្រធាន
៤- ឯកឧត្តម **ឃិច សមិទ្ធិ** មេធាវីប្រចាំក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
៥- លោក **ឯក ម៉ិនថា** អគ្គនាយករងបច្ចេកទេសវប្បធម៌ក្រ.វ.វ.ស. សមាជិក
៦- លោក **ម៉ុក ខេមរ៉ា** ប្រធាននាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិក
ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
៧- លោក **ម៉ុក ម៉ូរគ្យ** ប្រធាននាយកដ្ឋានសិល្បៈភាពយន្តក្រ.វ.វ.ស. សមាជិក
៨- លោក **ភាន មុរ៉ាមី** ប្រធាននាយកដ្ឋាននីតិកម្មក្រ.វ.វ.ស. សមាជិក
៩- លោក **ហេង ឡុង** ប្រធានសមាគមសិល្បករស្ម័គ្រចិត្តជួយសង្គម សមាជិក
១០- លោក **ទូច សុឃៈ** ប្រធានសមាគមពិធីករ ពិធីការិនីកម្ពុជា សមាជិក

| | | | |
|---|---|---|---|
| ១១- លោក | **ឆាយ យោធិន** | អនុប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធក្រ.វ.វ.ស. | សមាជិក |
| ១២- លោក | **គង់ សុទ្ធារិទ្ធិ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការវប្បធម៌ អន្តរជាតិនិងកិច្ចការអាស៊ានក្រ.វ.វ.ស. | សមាជិក |
| ១៣- លោក | **តាន់ សំបូរ** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅក្រ.វ.វ.ស. | សមាជិក |
| ១៤- លោក | **ម៉ុនថន សុខាណារិទ្ធ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការវប្បធម៌ អន្តរជាតិនិងកិច្ចការអាស៊ានក្រ.វ.វ.ស. | សមាជិក |
| ១៥- លោក | **ឱក តារារិទ្ធ** | អនុប្រធានកា.នាយកដ្ឋានសិល្បៈភាពយន្តក្រ.វ.វ.ស. | សមាជិក |

ក្រុមលេខាធិការដ្ឋាន មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យតាមដាន ប្រមូលព័ត៌មាននិងសកម្មភាពទាំងឡាយ ដែលនាំឲ្យប៉ះពាល់ដល់សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់ជាតិ និងសីលធម៌សង្គម
- ពិនិត្យសិក្សាលើអង្គហេតុ អង្គច្បាប់ និងលើកយោបល់ជូនក្រុមប្រឹក្សាពិន័យនិងលើកសរសើរ ដើម្បីពិនិត្យវាយតម្លៃ និងសម្រេច
- រៀបចំសំណុំឯកសារជូនក្រុមប្រឹក្សាពិន័យនិងលើកសរសើរ ដើម្បីពិនិត្យនិងសម្រេចក្នុងការដាក់ពិន័យ ឬការលើកសរសើរ
- ធ្វើការអប់រំ ណែនាំ ទប់ស្កាត់ និង/ឬដាក់ពិន័យ ចំពោះអ្នកដែលបានធ្វើសកម្មភាពនាំឱ្យប៉ះពាល់ដល់សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់ជាតិ និងសីលធម៌សង្គម តាមការសម្រេចរបស់ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ
- ផ្តល់លិខិតសរសើរ និង/ឬគ្រឿងឥស្សរិយយស លើកទឹកចិត្តជូនអ្នកដែលបានធ្វើសកម្មភាពរួមចំណែកលើកកម្ពស់សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់ជាតិ និងសីលធម៌សង្គម តាមការសម្រេចរបស់ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ
- សហការនិងសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាន ការវិភាគ ការវាយតម្លៃ ការអប់រំផ្សព្វផ្សាយ និងការអនុវត្ត
- តាមដាននិងដោះស្រាយវិវាទផ្សេងៗពាក់ព័ន្ធសកម្មភាពសិល្បៈ ប្រពៃណី ទំនៀមទម្លាប់ និងសីលធម៌សង្គម
- ធ្វើរបាយការណ៍អំពីសភាពការណ៍និងវឌ្ឍនភាពការងារ ជូនក្រុមប្រឹក្សាពិន័យនិងលើកសរសើរ
- បំពេញការងារផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាពិន័យនិងលើកសរសើរប្រគល់ជូន។

**ប្រការ៣**.-

ក្រុមលេខាធិការដ្ឋាននេះ អាចស្នើសុំជ្រើសរើសសមាជិកបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាពិន័យនិងលើកសរសើរ។

អនុប្រធាន និងសមាជិកនៃក្រុមលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមលេខាធិការដ្ឋាន។

**ប្រការ៤**.-

ក្រុមប្រឹក្សាពិន័យនិងលើកសរសើរនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្រាប់ដំណើរការការងាររបស់ខ្លួន។

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាពិន័យនិងលើកសរសើរ ប្រធាន អនុប្រធាន និងសមាជិកក្រុមលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាពិន័យនិងលើកសរសើរ។

**ប្រការ៥**.-

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អធិការនៃអធិការដ្ឋាន អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ភឿង-សកុណា**

**កន្លែងទទួល៖**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ